01086144

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 04 / 2015
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ០៥ ខែ មីនា ឆ្នាំ ២០១៥

## សវនាការលើអង្គសេចក្តី - ថ្ងៃ ២៥៣

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Matthew McCARTHY**

| |
|---|
| **<u>កំណត់ហេតុអ្នកចូលរួម</u>** |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN, ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ាង លោក Matthew J. McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោកស្រី ជា លាង, លោក Nicholas KOUMJIAN, លោក Dale LYSAK , កញ្ញា សុង ឆវ័ន្ត, លោក Vincent de Wilde d'ESTMAEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោកស្រី |

| |
|---|
| ទី ស្រីនណា, លោក ហុង គីមសួន , លោកស្រី ស៊ីន សុវ៉ន |
| សាក្សី/ដើមបណ្តឹង ៖ វ៉ាន់ សឿន (2-TCW-847), លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សា) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា ស្រី ណាក់, កញ្ញា សំ មករា, លោក លី សុតុល្យ , លោក Yassir Khalid AL-KHUDARYI |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០៣ | បញ្ចប់ម៉ោង៖ ១៥.៥១ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៤ | បញ្ចប់ម៉ោង៖ ១០.៤០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៥១ | បញ្ចប់ម៉ោង៖ ១៣.៤១ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤២ | បញ្ចប់ម៉ោង៖ ១៥.០៨ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ០៦ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៤ | ០៩.០៥ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៥ | ០៩.០៦ |
| ការជូនដំណឹងអំពីកិច្ចប្រជុំរៀបចំសវនាការ | អង្គជំនុំជម្រះ | ០៩.០៧ | ០៩.០៨ |
| ការតាំងសំណួរទៅកាន់សាក្សី វ៉ាន់ សឿន (2-TCW-847) | មេធាវីការពារក្តី នួន ជា<br><br>មេធាវីកាពារ ខៀវ សំផន<br>អង្គជំនុំជម្រះ | ០៩.០៨<br>១១.៣៣<br>១០.៤១<br>១១.៣២ | ១០.១៣<br>១១.៣៧<br>១១.២៨<br>១១.៣៣ |
| សំណើរបស់ នួន ជា ស្នើសុំចុះទៅពិនិត្យមន្ទីរសន្តិសុខក្រាំងតាចាន់ | មេធាវីការពារក្តី នួន ជា | ០៩.៤៣ | ០៩.៤៦ |
| សំណើរបស់ នួន ជា ស្នើសុំឱ្យធ្វើសវនាការជាអសាធារណៈ | មេធាវីការពារក្តី នួន ជា | ១១.២៨ | ១១.២៩ |

| | | | |
|---|---|---|---|
| សំណើរបស់ នួន ជា និង ខៀវ សំផន ស្នើសុំឱ្យធ្វើកិច្ចប្រជុំរៀបចំសវនាការជាសាធារណៈ | មេធាវីការពារក្តី នួន ជា<br>មេធាវីកាពារ ខៀវ សំផន | ១១.៤២<br>១១.៤៦ | ១១.៤៥<br>១១.៤៦ |
| កិច្ចប្រជុំរៀបចំសវនាការ | អង្គជំនុំជម្រះ | ១៣.៤១<br>១៤.២៩ | ១៣.៤៦<br>១៤.៣០ |
| | មេធាវីការពារក្តី នួន ជា | ១៣.៤៦<br>១៥.៣៥<br>១៥.៤៤ | ១៤.១៥<br>១៥.៤០<br>១៥.៤៦ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៤.១៦<br>១៥.៤០ | ១៤.២៨<br>១៥.៤៤ |
| | សហព្រះរាជអាជ្ញា | ១៤.៣០<br>១៥.៤៦ | ១៥.២១<br>១៥.៤៩ |
| | សហមេធាវីនាំមុខ | ១៥.២១<br>១៥.៤៩ | ១៥.៣៣<br>១៥.៥០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីបានរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែមេធាវីអន្តរជាតិការពារក្តីឱ្យលោក ខៀវ សំផន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ក្នុងការលះបង់សិទ្ធចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួន ស្ថិតនៅខាងក្រោមសាលសវនាការ។

**ការជូនដំណឹងអំពីកិច្ចប្រជុំរៀបចំសវនាការ**

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា សវនាការស្តាប់សក្ខីកម្ម 2-TCW-803 នឹងត្រូវផ្អាក ដោយមូល

ហេតុថាភាគីពាក់ព័ន្ធដទៃទៀតមិនមានលទ្ធភាព និងពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យអានឯកសារដែលពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់សាក្សី 2-TCW-803 និងដោយសារអង្គជំនុំជម្រះរៀបចំធ្វើកិច្ចប្រជុំរៀបចំសវនាការនេះ។

**ការតាំងសំណួរទៅកាន់សាក្សី វ៉ាន់ សឿន (2-TCW-847)**

មេធាវីការពារ នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានធ្វើការតាំងសំណួរទៅកាន់សាក្សី។

**សំណើរបស់ នួន ជា ស្នើសុំចុះទៅពិនិត្យមន្ទីរសន្តិសុខក្រាំងតាចាន់**

មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យភាគីទាំងអស់ចុះទៅពិនិត្យមើលមន្ទីរសន្តិសុខក្រាំងតាចាន់ ឱ្យបានជាក់ស្តែង និងព័ត៌មានលម្អិតអំពីមន្ទីរសន្តិសុខក្រាំងតាចាន់។ អង្គជំនុំជម្រះជូនដំណឹងថាខ្លួននឹងសម្រេចលើសំណើនេះនាពេលសមស្របខាងមុខ។

**សំណើរបស់ នួន ជា ស្នើសុំអោយធ្វើសវនាការជាអសាធារណៈ**

មេធាវីការពារក្តី នួន ជា ស្នើសុំតាំងសំណួរទៅកាន់សាក្សី 2-TCW-847 នៅក្នុងសវនាការអសាធារណៈ ដើម្បីជៀសវាងនូវការរំលោភបំពានលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលមិនឱ្យបញ្ចេញអត្តសញ្ញាណរបស់ជនរងគ្រោះដោយសារអំពើបំពារបំពានលើផ្លូវភេទ។ អង្គជំនុំជម្រះបានយល់ព្រមតាមសំណើ។ អង្គជំនុំជម្រះបានបង្គាប់ឱ្យសាធារណជនទាំងអស់ដែលមានវត្តមាននៅក្នុងកន្លែងសម្រាប់សាធារណជនឱ្យចាកចេញពីសាលសវនាការ។ អង្គជំនុំជម្រះក៏បានបង្គាប់ឱ្យបុគ្គលិកសោតទស្សន៍ផ្តាច់ប្រព័ន្ធសម្លេង និងរូបភាពនៃកិច្ចដំណើការនីតិវិធីក្នុងអំឡុងពេលនេះផងដែរ។

**សំណើរបស់ នួន ជា និង ខៀវ សំផន ស្នើសុំឱ្យធ្វើកិច្ចប្រជុំរៀបចំសវនាការជាសាធារណៈ**

មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើកិច្ចប្រជុំរៀបចំសវនាការជា សាធារណៈ។ មេធាវីការពារក្តី ខៀវ សំផន បានគាំទ្រទៅលើសំណើរបស់មេធាវីការពារក្តី នួន ជា។ អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើ ដោយសារប្រយោជន៍សាធារណជន ប៉ុន្តែភាគីត្រូវតែគោរពតាមភាពសម្ងាត់នៃឯកសារនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយផ្អែកតាមឯកសារ E319/7។

**កិច្ចប្រជុំរៀបចំសវនាការ**

**សំណើរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយពីសំណុំរឿង ០០៣ និង ០០៤**

មេធាវីការពារក្តី នួន ជា បានបង្ហាញទឡ្ហីករណ៍ថាខ្លួនពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការអានឯកសារ និងវិភាគទៅលើឯកសារពីសំណុំរឿង ០០៣ និង ០០៤ ដែលបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញានោះទេ ហើយថាឯកសារខ្លះនៅក្នុងចំណោមឯកសារទាំងនោះមិនពាក់ព័ន្ធឡើយ។ មេធាវីការពារក្តី នួន ជា

បានស្នើសុំឱ្យអង្គជំនុំជម្រះផ្អាកកិច្ចដំណើរការនីតិវិធីបណ្តោះអាសន្ន ដើម្បីឱ្យក្រុមមេធាវីការពារក្តីមានពេលវេលាពិនិត្យមើលឯកសារពីសំណុំរឿង ០០៣ និង ០០៤ ដែលបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញា។

មេធាវីការពារក្តី ខៀវ សំផន បានធ្វើការកត់សម្គាល់ពីកង្វះខាតពេលវេលា និងធនធានរបស់ខ្លួនក្នុងការរៀបចំការការពារក្តី និងតម្រូវការពេលវេលាបន្ថែម ដើម្បីពិនិត្យទៅលើឯកសារដែលបានដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤។

អង្គជំនុំជម្រះបានសួរទៅមេធាវីការពារក្តី អំពីចំនួនពេលវេលាបន្ថែមដែលខ្លួនត្រូវការ ក្នុងការពិនិត្យទៅលើឯកសារ។ មេធាវីការពារក្តី នួន ជា បានលើកឡើងថាខ្លួនមិនអាចឆ្លើយតបនូវចម្លើយជាក់លាក់ក្នុងពេលនេះ បាននោះទេ។ មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំពេលវេលាចំនួន ៦ សប្តាហ៍។ សហព្រះរាជអាជ្ញា បានកត់សម្គាល់អំពីភាពមិនត្រូវគ្នារវាង សំណើសុំពេលវេលាបន្ថែមរបស់មេធាវីការពារក្តីក្នុងការពិនិត្យទៅលើឯកសារ និងសំណើសុំការដាក់បង្ហាញឯកសារបន្ថែមពីសំណុំរឿងផ្សេង។

សហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួននឹងមិនដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរទៅលើសំណើរបស់មេធាវីការពារក្តីនោះទេ។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា ការផ្លាស់ប្តូរវគ្គនៃអង្គហេតុសម្រាប់ជំនុំជម្រះគឺនឹងប៉ះទង្គិចជាមួយនឹងបញ្ហានៃការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ហើយបញ្ហានេះគឺសម្រេចទៅលើសហចៅក្រមស៊ើបអង្កេតក្នុងការដាក់បង្ហាញឯកសារ។

បញ្ហាបន្ថែមទៀត៖

- មេធាវីការពារក្តី នួន ជា បានស្នើឱ្យមានការអះអាងពីអង្គជំនុំជម្រះថា ខ្មែរក្រោមនឹងមិនស្ថិតនៅក្នុង "ក្រុមមនុស្សជាក់លាក់" នៅក្នុងសំណុំរឿង ០០២/០២ នោះទេ។ សហព្រះរាជអាជ្ញា ជំទាស់ក្នុងការដកចេញនូវភស្តុតាងនៃការវាយប្រហារទៅលើខ្មែរក្រោម ដោយសារការវាយប្រហារទៅលើសត្រូវ គឺជាផ្នែកមួយនៃគោលនយោបាយខ្មែរក្រហម។
- មេធាវីការពារក្តី នួន ជា បានស្នើឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់បង្ហាញនូវភស្តុតាងបន្ថែមដែលពាក់ព័ន្ធពីសំណុំរឿង ០០៣ និង ០០៤។ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងអំពីតម្រូវការដែលនឹងអាចកើតមាន ក្នុងការហៅសាក្សីមួយចំនួនមកផ្តល់សក្ខីកម្មម្តងទៀតប្រសិនបើមិនមានការដាក់បង្ហាញឯកសារបន្ថែមពីសំណុំរឿង ០០៣ និង ០០៤។ មេធាវីការពារក្តី ខៀវ សំផន ក៏បានកត់សម្គាល់ផងដែរថាឯកសារមួយចំនួនមិនមានការបកប្រែជាភាសាបារាំងនោះទេ។ សហមេធាវីនាំមុខ បានលើកឡើងថាវាជាផលប្រយោជន៍សម្រាប់

ដើមបណ្តឹងរដ្ឋប្បវេណីដែលថាឯកសារគឺត្រូវដាក់បង្ហាញច្រើនតាមដែលអាចធ្វើបាន។ ម្យ៉ាងទៀត សហមេធាវីនាំមុខក៏បានលើកឡើងដែរថា សហចៅក្រមស៊ើបអង្កេតគួរតែកាត់បន្ថយលក្ខណ្ឌនៃការដាក់បង្ហាញឯកសារទាំងនេះ។ មេធាវីការពារក្តី នួន ជា បានស្នើឱ្យសហចៅក្រមស៊ើបអង្កេតដាក់បង្ហាញឯកសារទាំងឡាយណាដែលពាក់ព័ន្ធជាមួយនឹងសំណុំរឿង ០០២។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5852 | | 00224787-00224792 00231672-00231677; 00234573-00234578 | Written Record of Interview of Witness SREI Than alias Duch | P | 00224792 | 00231677 | 00234578 |
| E319.1.33 | | 00968170-00968196; 00980277-00980305; 00982607-00982632 | Written Record of Interview of VANN Soeun វ៉ាន់ សឿន (Note: The Defence Counsel for KHIEU Samphan - Mr. KONG SAM ONN – did not provide the ERN numbers for the issues that were raised. ERN 00980278 was not expressly mentioned) | SC | 0096818600968187 | 00980278 00980294 00980295 | 00982622 00982623 |
| E3/5845 | | 00165351-00165358; 00223207-00223213; 00490905-00490913 | Written Record of Interview of VANN Soeun វ៉ាន់ សឿន (Note: The Defence Counsel for KHIEU Samphan - Mr. KONG SAM ONN – did not provide the ERN numbers for the issues that were raised. ERN 00223208 was not expressly mentioned) | P | | 00223208 | |
| E3/4846 | | 00527717-00527770; 00527771-00527796; 00943267-00943276 | Interview by Mr. Chhoung Sophearith and Mr. Ea Meng-try | P | 00527731 | 00527778 | 00943268 |
| E319.1.32 | | 00980096-00980123; 00983566-00983590; 00988934-00988960 | Written Record of Witness Interview HUL Hoeun (81 | SC | 00980109 | 00983577 | 00988946 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។
- សម្រេចធ្វើកិច្ចប្រជុំរៀបចំសវនាការ ជំនួសការចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សី 2-TCW-803 និងបង្គាប់ឲ្យនាំសាក្សី 2-TCW-803 ត្រលប់ទៅលំនៅដ្ឋានគាត់វិញចុះ។

- សម្រេចតាមសំណើរបស់មេធាវីការពារក្តី នួន ជា ដែលបានស្នើសុំស្តាប់ផ្នែកនៃសក្ខីកម្មរបស់សាក្សី 2-TCW-847 នៅក្នុងសវនាការជាអសាធារណៈ និងមិនអនុញ្ញាតឱ្យបង្ហាញអត្តសញ្ញាណរបស់ជនរងគ្រោះនៃការបំពារបំពានផ្លូវភេទ។
- សម្រេចអនុញ្ញាតតាមសំណើរបស់មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន ដែលបានស្នើសុំឱ្យធ្វើកិច្ចប្រជុំរៀបចំសវនាការជាសាធារណៈ។
- សម្រេចបិទកិច្ចប្រជុំរៀបចំសវនាការ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ មកសាលសវនាការវិញឱ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៥ ។

| **<u>កាលវេលាសវនាការបន្ត</u>** |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ីវម៉ិច** Matthew McCARTHY